ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
**Ministry of Commerce**
No. ១៩៣ MOC / SM 2006

# ប្រកាស

## ស្តីពីការបង់កំរៃគ្រប់គ្រងការនាំចេញ (EMF) សំរាប់សំលៀកបំពាក់អនាម័យ ដែលប្រើតែមួយលើក រួចហើយបោះចោល

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម
- យោងតាមចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០០៦
- បានឃើញប្រកាសលេខ ២៨៥ ព.ណ.បអពប្រក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០០៥ ស្តីពីការកំណត់កំរៃគ្រប់គ្រងការ នាំចេញ
- យោងតាមការចាំបាច់នៃការនាំចេញផលិតផលរបស់កម្ពុជាក្នុងដំណាក់កាលថ្មី

## សំរេច

**ប្រការ១:** ការប្រមូលកំរៃគ្រប់គ្រងការនាំចេញ (Export Management Fees - EMF) ត្រូវបានអនុវត្តសំរាប់សំលៀកបំពាក់អនាម័យដែលប្រើតែមួយលើក រួចហើយបោះចោល (Disposable and Protective Products) ដូចការនាំចេញសំលៀកបំពាក់ធម្មតាដែរ ។

**ប្រការ២:** ចំពោះសំភារៈបន្ទាប់បន្សំដែលភ្ជាប់ជាមួយនឹងសំលៀកបំពាក់ខាងលើ ហើយប្រើប្រាស់តែមួយលើកដូចគ្នា ត្រូវបានលើកលែងការប្រមូលកំរៃគ្រប់គ្រងការនាំចេញ (EMF) ។

**ប្រការ៣:** កំរៃដែលលើកលែងក្នុងប្រការ "២" ខាងដើមត្រូវបានអនុវត្តសំរាប់គ្រប់ទិសដៅនាំចេញទាំងអស់ របស់ផលិតផលកម្ពុជា ។


Ministry of Commerce
20 A & B Preah Norodom Boulevard
Phnom Penh 12205
Kingdom of Cambodia

Senior Minister's Cabinet
Tel: (855) 23 427 358/214 946
Fax: (855) 23-213-288/991-708
E-mail: moccabdir@yahoo.com
Downloaded from http://www.khmerlaws.com

**ប្រការ៤:** នាយិកាខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាលហិរញ្ញវត្ថុ អគ្គាធិការ ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ប្រធាននាយកដ្ឋានអាស៊ាន និង អង្គការអន្តរជាតិ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០០៦

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចម្លងជូន</u> :**

- ខុទ្ទកាល័យ **សម្តេចនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- ទីចាត់ការគយ និង រដ្ឋាករ
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- រោងចក្រកាត់ដេរសំលៀកបំពាក់នៅកម្ពុជា "ដើម្បីសហការអនុវត្តន៍"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Ministry of Commerce
20 A-B Preah Norodom Boulevard
Phnom Penh 12205

Senior Minister's Cabinet
Tel: (855) 23 427 358/214 946
Fax: (855) 23-213-288/991-708

Downloaded from http://www.khmerlaws.com